ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# គម្រោងចិញ្ចឹមមេជ្រូកពូជយកកូនលក្ខណៈគ្រួសារ







រៀបចំដោយ៖ គណៈកម្មការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃធនាគារ អេ.អ.ឌី.ប៊ី, ២០២២

# សេចក្តីសង្ខេបនៃគម្រោង

- **ទំហំរោងជ្រូក** ÷ ទទឹង៧ម៉ បណ្តោយ ៣៨ម៉ កំពស់៤ម៉
- **ចំនួនមេជ្រូក** ÷ ដាក់មេជ្រូក៣០ក្បាល
- **មេបាជ្រូក** ÷ ជ្រើសរើសមេបាល្អ ទិញពីកសិដ្ឋានធំៗក្នុងស្រុក ដែលមានប្រវត្តិ និងប្រភពពូជច្បាស់លាស់ អាចបង្កើតកូនបាន ៣៣០ក្បាល/វគ្គ(៥ខែ) និង ៧៩២ក្បាល/ឆ្នាំ
- **រយៈពេលចិញ្ចឹម** ÷ ដើម ១១៣ថ្ងៃ មេជ្រូកបំបៅដោះកូនដល់អាយុ ២៥ថ្ងៃទើបផ្តាច់ដោះ (៧ទៅ១០ថ្ងៃមេជ្រូករកឈ្មោលទៀត) និងចិញ្ចឹមឱ្យរៀនស៊ីចំណីដល់អាយុ៣៥ថ្ងៃ ទម្ងន់ចន្លោះពី ៧ទៅ៨ គ.ក្រ ទើបលក់ចេញ។
- **អត្រាស្លាប់** ÷ ៣% (មេជ្រូកជាទូទៅអាចផ្តល់កូនបានចន្លោះពី១០ ទៅ១៣ក្បាល ដោយការសង្កេតជាមធ្យមមេជ្រូកអាចផ្តល់កូនសម្រាប់លក់ចេញបាន ១១ក្បាល/មេ
- **រយៈពេលផ្តល់កូន** ÷ ១ឆ្នាំមេជ្រូកអាចផ្តល់កូនបាន២,៤ ដង មេជ្រូកមួយក្បាលអាចផ្តល់កូនបាន១០ដង (ការថែទាំល្អ)
- **រដូវកាលចិញ្ចឹម** ÷ អាចចិញ្ចឹមបានពេញមួយឆ្នាំ អាស្រ័យលើតម្លៃលើទីផ្សារ និងតម្រូវការកូនជ្រូក
- **ទីផ្សារ** ÷ ឈ្មួញចុះទិញដល់ទីកន្លែង (តែមិនឱ្យចូលក្នុងកសិដ្ឋានដាច់ខាត) ត្រូវរងចាំទទួលកូនជ្រូកមុខកសិដ្ឋាន
- **តម្លៃ** ÷ ពី ៣២០,០០០រៀល ដល់ ៤០០,០០០រៀល/ក្បាល (តម្លៃឡើងចុះអាស្រ័យតម្លៃទីផ្សារជ្រូកសាច់រស់)
- **ទុន** ÷ សម្រាប់ការចិញ្ចឹមមេជ្រូក ៣០ក្បាល បាជ្រូក១ក្បាល សាងសង់រោងជ្រូក១ខ្នង ទ្រុងដាក់មេដើម មេបំបៅដោះ ព្រមទាំងសម្ភារប្រើប្រាស់ ផ្សេងៗលើផ្ទៃដីផ្ទាល់ខ្លួនដែលមានស្រាប់ ត្រូវការដើមទុនសរុបចំនួន÷**២៣៣,៥១៧,៩៤០**រៀល ក្នុងនោះ÷

| ចំណាយលើការរៀបចំទ្រុង | ចំណាយលើការចិញ្ចឹម-ថែទាំ | តម្រូវការទុនសរុប |
|---|---|---|
| **113,635,000** រៀល | **119,882,940** រៀល | **123,517,940** រៀល |

➢ ការវិភាគសេដ្ឋកិច្ចលើការចិញ្ចឹមមេជ្រូកពូជ៣០ ក្បាលសម្រាប់ផលិតកូនលក់ក្នុងរយៈពេលមួយឆ្នាំដែលអាចទទួលកូនបាន ២,៤ដង/ឆ្នាំ ស្មើនឹង ៧៩២កូនជ្រូក÷

| ចំណាយ | ចំណូល | ចំណេញ |
|---|---|---|
| **127,157,940** រៀល | **269,280,000** រៀល | **142,122,060** រៀល |

## ១- សេចក្តីផ្តើម

ការចិញ្ចឹមជ្រូករបស់កសិករនៅកម្ពុជាក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ បានទទួលរងនូវវិបត្តិជម្ងឺប៉េស្ត ជ្រូកអាហ្វ្រិចដ៏កាចសាហាវដែលធ្វើឱ្យកសិដ្ឋានតូច ធំ និងការចិញ្ចឹមលក្ខណៈគ្រួសារមួយចំនួនធំបាត់បង់ ជ្រូក ខាតបង់ថវិកាស្ទើរទាំងស្រុង។ កសិករខ្លះមិនមានដើមទុនដើម្បីចាប់ផ្តើមចិញ្ចឹមឡើងវិញ បានធ្វើឱ្យ ការផ្គត់ផ្គង់សាច់ជ្រូកលើទីផ្សារមានការថយចុះ តម្លៃកើនឡើងខុសពីឆ្នាំមុនៗដែលមិនទាន់ផ្ទុះជំងឺប៉េស្ត អាហ្វ្រិច។ បច្ចុប្បន្នស្ថានភាពនៃការរាលដាលជម្ងឺឆ្លងបានធូរស្រាល មានកសិដ្ឋានចិញ្ចឹមជ្រូកមួយចំនួនតូច ដែលជៀសផុតនិងទប់ស្កាត់បាននូវជំងឺនេះ បាននិងកំពុងខំប្រឹងពង្រីកការចិញ្ចឹមឡើងវិញ ដើម្បីចែកចាយ កូនជ្រូកពូជ និងជ្រូកសាច់ទៅកសិករផ្សេងទៀតយកទៅចិញ្ចឹម ដោយពង្រឹកនូវវិធានការជីវៈសុវត្ថិភាព យ៉ាងខ្ជាប់ខ្ជួនផងដែរ។

ដើម្បីជម្រុញឱ្យការចិញ្ចឹមជ្រូកកាន់តែប្រសើរឡើងប្រជាកសិករចាំបាច់ត្រូវយល់ដឹងអំពីបច្ចេកទេស ចំណេះជំនាញ និងបទពិសោធន៍ថ្មីៗបន្ថែមទៀត ពិសេសផ្តោតយ៉ាងខ្លាំងទៅលើវិធានការជីវៈសុវត្ថិភាព ដើម្បីទប់ស្កាត់ជំងឺដែលមានហានីភ័យខ្ពស់ ជាក់ស្តែងជម្ងឺប៉េស្តជ្រូកអាហ្វ្រិចមិនទាន់មានវ៉ាក់សាំង និងថ្នាំ ព្យាបាលនៅឡើយ។

ដើម្បីចិញ្ចឹមមេជ្រូកពូជផលិតកូនលក់ទទួលបានជោគជ័យ និងផ្តល់ទិន្នផលខ្ពស់ទាមទារឱ្យកសិករ ត្រូវគិតគូរពី÷

- ការជ្រើសរើសពូជ ការបង្កាត់ពូជ
- បច្ចេកទេសផ្តល់ទឹក ចំណី ថ្នាំការពារ ព្យាបាល រៀបចំទ្រុងត្រឹមត្រូវសមស្របទៅតាមបច្ចេកទេស
- ការផ្តល់កម្មវិធីវ៉ាក់សាំងការពារជំងឺដល់ជ្រូក
- ទីតាំងភូមិសាស្ត្រ បរិយាកាស របស់កសិដ្ឋានចិញ្ចឹម
- វិធានការជីវៈសុវត្ថិភាព និងការថែទាំ។ល។

## ២-លក្ខណៈជីវសាស្ត្រ

### ២.១. មានសមត្ថភាពបង្កកំណើតខ្ពស់ ÷

មេជ្រូកផ្តល់កូនបានពី២-២.៤ដង/ឆ្នាំ (៨-១២ក្បាល/ដង មេខ្លះផ្តល់កូនពី ១៨-២៤ក្បាល/ដង)។ មេជ្រូកអាចផលិតទឹកដោះបាន ២០០-៤០០លីត្រ/ដង(៤គក្រ ទឹកដោះអាចផ្តល់ភាពលូតលាស់ដល់កូន ជ្រូក ១គក្រទម្ងន់រស់)។

**២.២. ការផ្តល់ចំណី÷**សន្ទស្សន៍នៃការប្រើប្រាស់ចំណី (FCR) ប្រមាណ ៣គក្រ បានទម្ងន់ ១គក្រ ជ្រូករស់ ។

### ២.៣. ការផ្តល់ទិន្នផល

-មេជ្រូកមួយក្បាលអាចផ្តល់កូនមធ្យម ១១ក្បាល

-ផ្តល់សាច់ក្រហម ៤៥-៥០% ពូជជ្រូកក្នុងស្រុក និង៥៥-៦០% ពូជជ្រូកពីបរទេស។

**២-៤.ការសម្របខ្លួន÷** តាមសភាពជាក់ស្តែងពូជជ្រូក យ៉កសៀរ-ឡែនជ្រេស សម្របខ្លួនបាននឹងស្ថានភាពស្រុកយើង។

## ៣-ការជ្រើសរើសពូជជ្រូកចិញ្ចឹម

មេជ្រូកពូជសម្រាប់ចិញ្ចឹមយកកូនត្រូវមាន ÷

-រូបរាង ÷ ខ្លួនវែង ភ្លៅធំ ទម្ងន់ធ្ងន់

-សន្ទស្សន៍នៃការប្រើប្រាស់ចំណីទាប (FCR) ធម្មតា= ៣,២-៣,៦គក្រ,ល្អ=១-២,៥គក្រ

-ចិញ្ចឹមរហ័សធំ ធាត់ ធន់នឹងជម្ងឺ

-ទិន្នផលសាច់ ដែលផ្តល់សាច់ក្រហមច្រើន-(ពណ៌ក្លូឡាប) សាច់ផុយ

-មានដោះ៦គូ ឡើង ក្បាលដោះល្អ មិនខ្វាក់ ចន្លោះដោះពីមួយគូទៅមួយគូ ស្មើៗគ្នា

-ចេះចិញ្ចឹមកូន សំបូរទឹកដោះ(សម្រាប់ជ្រូកបា ត្រូវមានគុណភាពទឹកកាមខ្ពស់)

## ៤-វិធីសាស្ត្រចិញ្ចឹម

វិធីសាស្ត្រនៃការចិញ្ចឹមមេជ្រូកពូជផលិតកូនគឺអាស្រ័យទៅលើស្ថានភាព ទីតាំងភូមិសាស្ត្រ ពូជជ្រូក ដោយការការចិញ្ចឹមមានលក្ខណៈខុសៗគ្នា÷

- ការចិញ្ចឹមបែបប្រពៃណី-យថាផល÷ ដោយផ្តល់ចំណីតែកាកសំណល់ផ្ទះបាយ កន្ទក់ និងចុងអង្ករ ដែលមានស្រាប់ក្នុងផ្ទះ គ្មានការប្រើប្រាស់ថ្នាំ វ៉ាក់សាំង
- ការចិញ្ចឹមបែបលក្ខណៈគ្រួសារ ÷ដោយផ្តល់ចំណី កាកសំណល់ផ្ទះបាយ វត្ថុធាតុដើមក្នុងភូមិ និងចំណីក្រុមហ៊ុនបន្តិចបន្តួចផងដែរ មានការប្រើប្រាស់ថ្នាំ និងវ៉ាក់សាំងខ្លះៗ
- ការចិញ្ចឹមបែបប្រពលវប្បកម្ម ឬបែបពាក់កណ្តាលឧស្សាហកម្ម÷ ដោយកសិករធ្វើទ្រុងត្រឹមត្រូវតាមលំនាំបច្ចេកទេស ការផ្តល់ចំណីមានគុណភាពល្អ (ចំណីរោងចក្រ) ឬការលាយចំណីផ្សំមានស្តង់ដារត្រឹមត្រូវ ការធ្វើវ៉ាក់សាំងមានកម្មវិធីច្បាស់លាស់ស្របតាមគោលការណ៍បច្ចេកទេស។

**ការផលិតកូនជ្រូកចែកចេញជា២ ផ្នែក ÷**

- ការផលិតកូនជ្រូកទុកធ្វើមេបាពូជបន្ត÷ ការបង្កាត់យកឈាមសុទ្ធ ឬ២ឈាម ដែលជាពូជសាយកូនសម្បូរទឹកដោះ ពូកែថែកូន ធន់នឹងជំងឺ ធន់នឹងអាកាសធាតុ ស្លូតងាយស្រួលចិញ្ចឹម (ពិសេសពូជជ្រូកយ៉កសៀរ (Yorkshire) និងឡែនជ្រេស (Landrace) សម្រាប់យកធ្វើមេពូជបន្ត) រីឯការផលិតកូនជ្រូកឈ្មោលទុកធ្វើបា ត្រូវរកពូជសាច់ក្រហមច្រើន ខ្នងធំក្រាស់ ត្រគាកធំល្អ ភ្លៅធំ រោមក្រាស់ ជើងធំ រឹងមាំ ចិញ្ចឹមឆាប់ធំ ធន់នឹងជំងឺ អាកាសធាតុ ពូកែស៊ី សម្រាប់ធ្វើបា (ពិសេសពូជ ឌុយ៉រក (duroc) ភីជ្រេន (Pie train) ហាមសៀរ (Hamshire) គេបង្កាត់ពូជទុកសម្រាប់តែធ្វើបា និងមេសម្រាប់ធ្វើពូជបន្ត មិនសម្រាប់ធ្វើមេជ្រូកផលិតកូនជ្រូកសាច់ទេ ព្រោះភាគច្រើនកូនតិច មិនសម្បូរទឹកដោះ និងកាច។ល។

➢ ការផលិតកូនជ្រូកទុកចិញ្ចឹមយកសាច់÷ ការបង្កាត់យកមេពូជសាយកូន ទឹកដោះច្រើន បង្កាត់ជាមួយបាពូជ ធន់ជំងឺ ឆ្អឹងធំ សាច់ក្រហមច្រើន ធន់នឹងជំងឺ FCR ទាប ពូកែស៊ី ដើម្បីបានកូនមកច្រើន ចិញ្ចឹមឆាប់ធំ ធន់នឹងជំងឺ មិនរើសចំណី និងមិនអាចធ្វើពូជបន្តបានទេ ព្រោះកាត់ទៅខាងបា ដែលជាពូជកូនតិច មិនសូវសម្បូរទឹកដោះ។ល។

## ៥-ការរៀបចំទ្រុង

ការរៀបចំទ្រុង និងទំហំទ្រុងគឺអាស្រ័យទៅតាមប្រភេទពូជជ្រូក និងតាមតំបន់ ឬទីតាំងជាក់ស្តែង និងធនធានផ្ទាល់ខ្លួន តែក៏ត្រូវមានផ្ទៃក្រឡាសមស្របដែរ÷





| ប្រភេទជ្រូក | ទំហំទ្រុង (ម៉ែត្រ) | កំពស់ទ្វារ (ម៉ែត្រ) |
|---|---|---|
| មេជ្រូកផើម/ មេបម្រុង | 0.65 x 2.20 | 1.00 |
| ជ្រូកបាមានកន្លែងសម្រាប់បង្កាត់ | 2.30 x 4.00 | 1.00 - 1.50 |
| មេជ្រូកកើតកូន និងបំបៅដោះ | 2.00 x 2.30 | 1.00 |
| កូនជ្រូកផ្តាច់ដោះ | 2.50 x 3.00 (សម្រាប់12ក្បាល) | 0.60 |

## ៦- ចំណីជ្រូក

ប្រភេទចំណីសម្រាប់សត្វជ្រូកមាន ÷កន្ទក់ ចុងអង្ករ ពោត សណ្តែក ត្រកួន ចកបាយទា កំប្លោក កន្ទុំថេត ផ្ទី ស្លឹកដំឡូងជ្វា ដំឡូងមី ស្លឹកបាស ស្លឹកម្រំ ដើមត្រាវនិងស្លឹក កំពិស កូនត្រីតូចៗ ក្បាលត្រី កាកសំណល់ផ្ទះបាយ បាយស្រា។ល។

-ការប្រើប្រាស់ចំណីសម្រេចពីក្រុមហ៊ុនសុទ្ធ១០០%

-ចំណីត្រូវមានសារធាតុចិញ្ចឹមចាំបាច់ដូចជា÷ ប្រូតេអ៊ីន ថាមពល វីតាមីន សារធាតុខនិជ និងទឹក។

<table>
<tr><th colspan="3">បរិមាណធាតុផ្សំចំណី ១០០គីឡូក្រាម</th><th colspan="2">តម្រូវការចំណីទៅតាមប្រភេទជ្រូក</th></tr>
<tr><th>សមាសភាពធាតុផ្សំចំណី</th><th>មេជ្រូក និងជ្រូកបា</th><th>ជ្រូកបំបៅដោះ</th><th>ប្រភេទជ្រូក</th><th>តម្រូវការចំណីប្រចាំថ្ងៃ (គិតជាគីឡូក្រាម)</th></tr>
<tr><td>ចុងអង្ករ</td><td>50</td><td>56</td><td>មេក្រមុំ</td><td>2.00 kg</td></tr>
<tr><td>កន្ទក់</td><td>30</td><td>20</td><td>ជ្រូកបា</td><td>2.00 - 2.50 kg</td></tr>
<tr><td>សណ្តែកសៀង</td><td>13</td><td>16</td><td>មេធើម</td><td>2.00 - 2.50 kg</td></tr>
<tr><td>ម្សៅត្រី</td><td>4</td><td>4</td><td>មេបំបៅកូន</td><td>2.00 - 4.00 kg</td></tr>
<tr><td>សំបកលៀសគ្រំ ខ្យង</td><td>2</td><td>3</td><td>មេផ្តាច់ដោះកូន</td><td>2.50 - 3.00 kg</td></tr>
<tr><td>ស្ករ</td><td>0</td><td>0</td><td>កូនជ្រូកនៅបៅដោះ</td><td>0.30 - 0.40 kg</td></tr>
<tr><td>ប្រេងចំអិន</td><td>0</td><td>0</td><td colspan="2" rowspan="4">កង្វះប្រូតេអ៊ីនៈ សត្វមិនសូវស៊ីចំណី (ព្រោះលក្ខណៈឆ្ងាញ់មាត់ថយចុះ) ការលូតលាស់យឺត ការបង្កកំណើតអន់ (ព្រោះកម្រិតរលាយទាប), ស្បែកស្ងួតនិងសុខភាពទន់ខ្សោយ។</td></tr>
<tr><td>អំបិល</td><td>0.50</td><td>0.50</td></tr>
<tr><td>ព្រីម៊ិច</td><td>0.50</td><td>0.50</td></tr>
<tr><td>**សរុប**</td><td>100</td><td>100</td></tr>
</table>

**តម្រូវការទឹក សម្រាប់ជ្រូក**

| ប្រភេទជ្រូក | បរិមាណទឹក( លីត្រ)/ថ្ងៃ | កម្រិតលំហូរទឹកពីក្បាលបឺត/ នាទី |
|---|---|---|
| មេធើម | ១៥-២៥ | ២ |
| មេបំបៅដោះ | ៣០-៤៥ | ២ |
| កូនជ្រូកបៅដោះ | ០,២-០,៤ | ០,៥-១ |
| កូនជ្រូកក្រោយផ្តាច់ដោះ | ២,៥-៥ | ២ |

## ៧- <u>ការថែទាំសុខភាពមេជ្រូក</u>

ការថែទាំ និងការផ្តល់ចំណីបានត្រឹមត្រូវដល់មេជ្រូកពេលមានគភ៌គឺមានសារសំខាន់ណាស់សម្រាប់ជួយឱ្យគភ៌ (Zygot) មានការរីកចម្រើន ហើយក៏អាចរក្សាកូនទាំងនោះឱ្យបានល្អ ÷

– ជួយឱ្យសារពាង្គកាយមេមានសារធាតុស្តុកទុកច្រើនដើម្បីបង្កើតជាទឹកដោះបំបៅឱ្យកូនផងដែរ
– មេជ្រូកដែលបង្កាត់ហើយក្នុងករណីដែលសីតុណ្ហភាព និងសំណើមខ្ពស់ចន្លោះរយៈពេល១-១៦ថ្ងៃដំបូង ធ្វើឱ្យអត្រាផ្តល់កូនបានតិច

– មួយសប្ដាហ៍មុនពេលកើតយើងអាចដូរចំណីរបស់មេជ្រូកពពោះមកជាចំណីមេចិញ្ចឹមកូនតែម្ដង (ដូរបន្តិចម្ដងៗចៀសវាងមេជ្រូករាក)។ ក្នុងរយៈពេល៣ថ្ងៃមុនពេលកើតកូន ត្រូវបន្ថយចំណីបន្តិចម្ដងៗរហូតនៅសល់តែ១គក្រ/ថ្ងៃមុនពេលកើត និងថែមចំណីបន្លែ ឬកន្ទក់ដល់មេជ្រូកដើម្បីចៀសវាងមេគៀនពិបាកសម្រាលកូន និងរលាកកន្សោមដោះ ។

– អនាម័យត្រូវធ្វើឡើងឱ្យបានល្អដើម្បីចៀសវាងមេជ្រូកចម្លងជំងឺដល់កូនតាមរយៈកត្តាផ្សេងៗ ប្រមាណជា៣-៦អាទិត្យមុនពេលកើត ដុសលាងសម្អាតមេជ្រូកដោយសាប៊ូ និងសម្អាតទ្រុងនៅថ្ងៃទី៥-៧ មុនពេលសម្រាល ។

– ថែទាំមេជ្រូកក្រោយពេលសម្រាល។ កន្លែងមេបង្កើតកូនត្រូវមានអាកាសធាតុសមស្រប បរិយាកាសមានខ្យល់ចេញចូលល្អ និងត្រូវមានសភាពស្ងប់ស្ងាត់។

– សីតុណ្ហភាពក្ដៅស្ទុះស្អាប់ធ្វើឱ្យមេជ្រូកពិបាកដកដង្ហើម ខ្ជិលប្រឹង បណ្ដាលឱ្យការបង្កើតមានសភាពយឺតយ៉ាវបណ្ដាលឱ្យថប់ដង្ហើមកូន។

– មុនពេលសម្រាលកូនយើងចាំបាច់ត្រូវសម្អាតប្រដាប់បន្តពូជមេជ្រូកជាមុនសិន ពិសេសចន្លោះយោនីនិងទ្វារធំ ព្រោះកន្លែងនេះមានសភាពកខ្វក់ដែលងាយចម្លងមេរោគបំផុត។

## ៨-<u>ការចាក់ថ្នាំវ៉ាក់សាំងការពារសុខភាពមេជ្រូក</u>

| **អាយុ/រយៈពេល** | **ប្រភេទថ្នាំ/វ៉ាក់សាំង** | **របៀបប្រើ** | **កម្រិតប្រើ** | **រំលឹក** |
|---|---|---|---|---|
| មុនបង្កាត់ ៦ ថ្ងៃ ឬផើមបាន៦០ថ្ងៃ | ត្រចៀកខៀវ (PRRS) | ចាក់សាច់ដុំ | 2cc/ក្បាល | ៦ខែម្ដង |
| ២ឬ៤សប្ដាហ៍មុនបង្កាត់ឬ២សប្ដាហ៍បន្ទាប់ពីកើតកូន | ប៉េស្ដ (CSF) | ចាក់សាច់ដុំ | 2cc/ក្បាល | (១ឆ្នាំម្ដង) |
| ១០ ថ្ងៃមុនផ្ដាច់ដោះ | ភីស៊ីវីធូ វីរុស | ចាក់សាច់ដុំ | 2cc/ក្បាល | ៦ខែម្ដង |
| ៤ សប្ដាហ៍មុនកើត | អ៊ុតក្ដាម (FMD) | ចាក់សាច់ដុំ | 2cc/ក្បាល | ៦ខែម្ដង |
| ១៨សប្ដាហ៍/ ៣សប្ដាហ៍មុនកើត | អូហ្សេស្គី (Aujeszky) | ចាក់សាច់ដុំ | 2cc/ក្បាល | ៦ខែម្ដង |
| ១០ថ្ងៃមុនកើត | Ivermectine,Flubendazole | ចាក់សើស្បែក | តាមការណែនាំ | ៦ខែម្ដង |

## ៩-ការប្រមូលផល÷

រយៈពេលនៃការចិញ្ចឹមមេជ្រូកយកកូន ជាមធ្យមអាចបង្កើតកូនបាន២,៤ដង/ឆ្នាំ ដោយចំណាយពេល៥ខែ/ សំបុក (១សំបុក ជាមធ្យមបានកូនជ្រូក ១១ក្បាល)។ កសិករអាចលក់ជាក់ស្តែងដោយអាស្រ័យលើគុណភាពកូនជ្រូក និងតម្លៃលើទីផ្សារ ។

**ការវិភាគសេដ្ឋកិច្ចលើការចិញ្ចឹមមេជ្រូកយកកូន ÷**

**ក)-ករណីចិញ្ចឹមមេជ្រូកពូជផលិតកូនបែបប្រពលវប្បកម្មនៅតាមផ្ទះ (កូនជ្រូក ៧៩២ក្បាល) ÷**

| បរិយាយ | ឯកត្តា | ចំនួន ឯកត្តា | តម្លៃ ១ឯកត្តា | ទឹកប្រាក់ សរុប(រៀល) | ចំនួន សារវិលោះ | ទឹកប្រាក់ សរុប(រៀល) |
|---|---|---|---|---|---|---|
| **១-ចំណូលសរុបពីការលក់កូនជ្រូកក្នុង១ឆ្នាំ** | | | | | | |
| ចំណូលពីការលក់កូនជ្រូក | ក្បាល | 792 | 340,000 | 269,280,000 | | **269,280,000** |
| **២-ចំណាយសរុប = ចំណាយប្រែប្រួល + ចំណាយមិនប្រែប្រួល/ថេរ** | | | | | | **127,157,940** |
| **២.ក.ចំណាយប្រែប្រួល** | | | | | | **119,882,940** |
| ចំណីសម្រេចជ្រូកធើម | គ.ក្រ | 22,770 | 2,300 | 52,371,000 | | 52,371,000 |
| ចំណីសម្រេចជ្រូកបំបៅដោះ | គ.ក្រ | 7560 | 2,366 | 17,886,960 | | 17,886,960 |
| ចំណីទឹកដោះមុនផ្តាច់ដោះ | ក្បាល | 792 | 990 | 784,080 | | 784,080 |
| ចំណីពីផ្តាច់ដោះដល់អាយុ ៣៥ថ្ងៃ | ក្បាល | 792 | 11,000 | 8,712,000 | | 8,712,000 |
| ថ្លៃអគ្គិសនី | KWh | 6000 | 720 | 4,320,000 | | 4,320,000 |
| ថ្លៃប្រេងបូមទឹក | លីត្រ | 720 | 5,000 | 3,600,000 | | 3,600,000 |
| ថ្នាំប្រើលើមេជ្រូក | ក្បាល | 30 | 8,000 | 240,000 | | 240,000 |
| ថ្នាំប្រើលើកូនជ្រូក | ក្បាល | 792 | 4,000 | 3,168,000 | | 3,168,000 |
| វ៉ាក់សាំងមេជ្រូក | ក្បាល | 30 | 104,400 | 3,132,000 | | 3,132,000 |
| វ៉ាក់សាំងកូនជ្រូក | ក្បាល | 792 | 6,200 | 4,910,400 | | 4,910,400 |
| កំលាំងពលកម្ម | ខែ | 800,000 | 12 | 9,600,000 | | 9,600,000 |
| ថ្លៃចំណីជ្រូកបា | គ.ក្រ | 1095 | 2,300 | 2,518,500 | | 2,518,500 |
| ថ្នាំសំលាប់មេរោគ | ខែ | 680,000 | 12 | 8,160,000 | | 8,160,000 |
| ដឹកជញ្ជូលឱ្យអតិថិជន | លើក | 12 | 40,000 | 480,000 | | 480,000 |
| **២.ខ.ចំណាយមិនប្រែប្រួល/ថេរ (ក្នុង១ឆ្នាំ)** | | | | **113,635,000** | | **7,275,000** |

| | | | | | | |
|---|---|---|---|---|---|---|
| រោងជ្រូក ស្នូកទឹក/ចំណី មេជ្រូក/កូនជ្រូក ក្បាលបឺតទឹក អំពិលភ្លើង ខ្សែភ្លើង ទ្រុងមេបំបៅដោះ ទ្រុងមេជើម ទុយោទឹក ស្បៃការពារសត្វល្អិត | រោង | 1 | 45,000,000 | 45,000,000 | 10 | 4,500,000 |
| ម៉ាស៊ីនបូមទឹក ប្រើបាន៥ឆ្នាំ | គ្រឿង | 1 | 5,200,000 | 5,200,000 | 5 | 1,040,000 |
| ស្រះទឹកសម្រាប់បង្ហូរលាមក | ស្រះ | 1 | 200,000 | 200,000 | 10 | 20,000 |
| ធុងបាញ់ថ្នាំសំលាប់មេរោគ | ធុង | 1 | 200,000 | 200,000 | 1 | 200,000 |
| បាជ្រូក | ក្បាល | 1 | 3,000,000 | 3,000,000 | 3 | 1,000,000 |
| មេជ្រូក | ក្បាល | 30 | 2,000,000 | 60,000,000 | 125 | 480,000 |
| ទុយោទឹក | ដុំ | 1 | 35,000 | 35,000 | 1 | 35,000 |
| **៣-ចំណេញសរុបលើមេជ្រូក ៣០ ក្បាល** | | | | | | **142,122,060** |
| **ការចំណាយដើមទុនក្នុងកូនជ្រូកមួយក្បាល** | | | | | | **160,553** |
| **ប្រាក់ចំណេញក្នុងកូនជ្រូកមួយក្បាល** | | | | | | **179,447** |

**ប្រភព**÷ ចុះសាកសួរកសិករចិញ្ចឹមជ្រូកផ្ទាល់នៅភូមិញ្ញោកើត ឃុំព្រៃចារ ស្រុកជើងព្រៃ ខេត្តកំពង់ចាម

**កំណត់សំគាល់** ÷ មិនទាន់គិតបញ្ចូលពីការលក់មេជ្រូក និងបាជ្រូក នៅពេលអស់លទ្ធភាពផលិតកូន

### ខ) ការវិភាគលើតម្លៃលក់/ឆ្នាំ

| ទិន្នផលកូនជ្រូក (ក្បាល)/ឆ្នាំ | តម្លៃកូនជ្រូក/ក្បាល(រៀល) | ចំណូលសរុប (រៀល) | ចំណាយសរុប (រៀល) | ចំណេញ (រៀល) | កំណត់សម្គាល់ |
|---|---|---|---|---|---|
| 792 | 360,000 | 285,120,000 | 127,157,940 | 157,962,060 | ទទួលបានកូន 11 ក្បាល/សំបុក |
| | 340,000 | 269,280,000 | 127,157,940 | 142,122,060 | |
| | 300,000 | 237,600,000 | 127,157,940 | 110,442,060 | |
| | 250,000 | 198,000,000 | 127,157,940 | 70,842,060 | |
| 432 | 360,000 | 155,520,000 | 119,169,540 | 36,350,460 | ទទួលបានកូន 6 ក្បាល/សំបុក |
| | 340,000 | 146,880,000 | 119,169,540 | 27,710,460 | |
| | 300,000 | 129,600,000 | 119,169,540 | 10,430,460 | |
| | 250,000 | 108,000,000 | 119,169,540 | (11,169,540) | |

*កំណត់សម្គាល់*

- ក្នុងករណីកូនជ្រូកទទួលបាន១១ក្បាល/សំបុក ការចំណាយលើ ថ្នាំ វ៉ាក់សាំង ចំណីច្រើន នាំឱ្យការចំណាយខ្ពស់ ចំណេញក៏ច្រើន
- ក្នុងករណីកូនជ្រូកទទួលបាន៦ ក្បាល/សំបុក ការចំណាយលើ ថ្នាំ វ៉ាក់សាំង ចំណីតិច នាំឱ្យការចំណាយតិច ចំណេញក៏តិច

**៨-និន្នាការតម្លៃ ÷**

តម្លៃលក់កូនជ្រូកចាប់ពី ៣២០,០០០រៀល ទៅ ៣៦០,០០០រៀល/ក្បាល។ នៅក្នុងថ្ងៃ២៤ មីនា ២០២២កន្លងទៅកសិករចិញ្ចឹមមេជ្រូកផលិតកូន លក់បានតម្លៃ៣៤០,០០០៛/ក្បាលទៅកសិករ នៅក្រៅស្រុកនិងក្នុងស្រុកជើងព្រៃ ខេត្តកំពង់ចាម ដើម្បីយកទៅចិញ្ចឹមបន្ត។

**៩-ហានិភ័យ ÷**

កសិករអ្នកចិញ្ចឹមមេជ្រូកផលិតកូនអាចប្រឈមនឹងហានិភ័យមួយចំនួន÷

**ក-ហានិភ័យផលិតកម្ម ÷** ទោះបីមានបទពិសោធន៍ក្នុងការចិញ្ចឹមជ្រូកយូរឆ្នាំក៏ដោយ ទិន្នផលដែលទទួលបានអាចទាបជាងការរំពឹងទុក ដោយសារការថែទាំមិនបានដិតដល់ល្អ គុណភាពចំណីមិនស្ថិតស្ថេរ ការរក្សាសីតុណ្ហនៅក្នុងរោងចិញ្ចឹមមិនបានល្អ (ក្តៅខ្លាំង ត្រជាក់ខ្លាំង) ជាពិសេសការរាលដាលជម្ងឺឆ្លងសត្វជ្រូក។ កសិករចិញ្ចឹមជ្រូកនៅខ្វះកម្លាំងពលកម្មជំនាញ ពុំសូវមានអ្នកដែលមានបច្ចេកទេស បទពិសោធន៍ពីស្ថាប័នជំនាញជួយណែនាំដិតដល់។

**ខ-ហានិភ័យទីផ្សារ ÷** ទាក់ទងលទ្ធភាពនៃការបាត់បង់ទីផ្សារ ឬតម្លៃដែលទទួលបានទាប ការធ្លាក់ចុះនៃការលក់ និងតម្លៃចំណីជ្រូកមានការកើនឡើង ចំនួនអ្នកប្រកួតប្រជែងក្នុងស្រុក ជាពិសេសការនាំសត្វជ្រូកចូលពីប្រទេសជិតខាងច្រើន ធ្វើឱ្យអ្នកចិញ្ចឹមជ្រូកសាច់ថយចុះ ពិបាកលក់កូនជ្រូក ។

**គ-ហានិភ័យហិរញ្ញវត្ថុ ÷** កសិករចិញ្ចឹមមេជ្រូកផលិតកូនមិនមានទុនគ្រប់គ្រាន់សម្រាប់វិនិយោគ និងប្រាក់បម្រុងសម្រាប់ទប់ទល់ហេតុការណ៍កើតឡើងដោយចៃដន្យ។

**ឃ-ហានិភ័យបរិស្ថាន ÷** ប៉ះពាល់ដល់ការរស់នៅរបស់អ្នករស់នៅជុំវិញកន្លែងចិញ្ចឹមបណ្ដាលមកពីក្លិនលាមក និងសម្លេងជ្រូកស្រែក។ ករណីកសិករចិញ្ចឹមជ្រូកពុំមានលទ្ធភាពសង់ទ្រុងជ្រូកនៅដាច់ដោយឡែកឆ្ងាយពីលំនៅដ្ឋាន កសិករត្រូវធ្វើអនាម័យសម្អាតទ្រុងជាប្រចាំ និងមានទីស្តុកលាមកជ្រូកឱ្យបានត្រឹមត្រូវ ឬបើមានលទ្ធភាពអាចសង់ជាឡជីវឧស្ម័នសម្រាប់ប្រើប្រាស់បានទៀតផង។

**១០-សេចក្តីសន្និដ្ឋាន ÷**

ជាទូទៅ អាជីវកម្មចិញ្ចឹមមេជ្រូកយកកូននេះមានផលចំណូលខ្ពស់ ប្រសិនបើកសិករចិញ្ចឹមជ្រូកមានបទពិសោធន៍ និងអនុវត្តតាមបច្ចេកទេសត្រឹមត្រូវ អាចទទួលបានទិន្នផលខ្ពស់ ថ្លៃដើមចំណាយទាបអាចប្រកួតប្រជែងជាមួយតម្លៃកូនជ្រូកនាំចូលពីបរទេស ប្រាក់ចំណូលនឹងមានការកើនឡើង។